ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ បព ៣៧ /២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃទស្សនកិច្ចផ្លូវការរបស់ ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស នៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋសិង្ហបុរី

តាមការអញ្ជើញរបស់ **ឯកឧត្តម បណ្ឌិត វីវៀន បាឡាគ្រីស្សណាន់** រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋសិង្ហបុរី **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជាបានអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋសិង្ហបុរី ពីថ្ងៃទី១០ដល់១១ ខែមីនា ឆ្នាំ២០២៦។

ក្នុងឱកាសទស្សនកិច្ចនេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានជួបសម្តែងការគួរសមចំពោះ **ឯកឧត្តម ឡរ៉េន វ៉ុង** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសិង្ហបុរី។ **ឯកឧត្តម នាយករដ្ឋមន្ត្រី ឡរ៉េន វ៉ុង** បានផ្តល់ការស្វាគមន៍យ៉ាងកក់ក្តៅ និងបញ្ជាក់ថាទស្សនកិច្ចនេះជាការឆ្លុះបញ្ចាំងពីមិត្តភាពដ៏ជិតស្និទ្ធរវាងប្រទេសទាំងពីរ ព្រមទាំងបានរួមចំណែកយ៉ាងសំខាន់ ក្នុងការបន្តធ្វើឱ្យកាន់តែស៊ីជម្រៅថែមទៀតនូវទំនាក់ទំនងទ្វេភាគីយូរអង្វែងរវាងកម្ពុជា និងសិង្ហបុរី។

**ឯកឧត្តម ប្រាក់ សុខុន** និង**ឯកឧត្តម បណ្ឌិត វីវៀន បាឡាគ្រីស្សណាន់** បានពិភាក្សាប្រកបដោយផ្លែផ្កាអំពីការលើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគីលើគ្រប់វិស័យ ចាប់ពីកិច្ចសហប្រតិបត្តិការនយោបាយ រហូតដល់កិច្ចសហការសេដ្ឋកិច្ច និងការតភ្ជាប់រវាងប្រជាជននិងប្រជាជន ព្រមទាំងស្វែងរកវិស័យថ្មីៗបន្ថែមទៀតសម្រាប់កិច្ចសហប្រតិបត្តិការ។

## កិច្ចសហប្រតិបត្តិការនយោបាយ

ឯកឧត្តមរដ្ឋមន្ត្រីការបរទេសទាំងពីរបានបញ្ជាក់សាជាថ្មីនូវការប្តេជ្ញារួម ក្នុងការជំរុញទំនាក់ទំនាក់ដ៏កក់ក្តៅដែលមានស្រាប់ ហើយបានសង្កត់ធ្ងន់អំពីសារសំខាន់នៃការប្រាស្រ័យទាក់ទងកម្រិតខ្ពស់ជាទៀតទាត់ ដែលជាកត្តាដ៏សំខាន់សម្រាប់ជំរុញភាពជាដៃគូរវាងប្រទេសទាំងពីរ ដែលកំពុងមានការរីកចម្រើន ។ ទស្សនកិច្ចផ្លូវការរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅប្រទេសសិង្ហបុរី នៅក្នុងខែមិថុនា ឆ្នាំ២០២៤ និងទស្សនកិច្ចផ្លូវការរបស់**ឯកឧត្តមនាយករដ្ឋមន្ត្រី ឡរ៉េន វ៉ុង** នៅកម្ពុជា នៅក្នុងខែកក្កដា ឆ្នាំ២០២៥ គឺជាព្រឹត្តិការណ៍ដ៏សំខាន់នៃមិត្តភាពដ៏យូរអង្វែងរវាងកម្ពុជា និងសិង្ហបុរី។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

**កិច្ចសហប្រតិបត្តិការការពារជាតិ និងសន្តិសុខ**

ឯកឧត្តមរដ្ឋមន្ត្រីទាំងពីរ បានកត់សម្គាល់ដោយក្តីពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ រវាងប្រទេសទាំងពីរលើវិស័យការពារជាតិ និងសន្តិសុខ ជាពិសេសក្នុងការដោះស្រាយបញ្ហាឧក្រិដ្ឋកម្មឆ្លងដែន។ ភាគីទាំងពីរបានបញ្ជាក់អំពីសារសំខាន់នៃការសម្របសម្រួល រវាងស្ថាប័នអនុវត្តច្បាប់នៃប្រទេសទាំងពីរបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាប្រឈមទាំងនេះ ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសិង្ហបុរី ដែលបន្តគាំទ្រការកសាងសមត្ថភាពកងយោធពលខេមរភូមិន្ទ។

**កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ច**

ភាគីទាំងពីរបានទទួលស្គាល់ថា មានសក្តានុពលជាច្រើនសម្រាប់ពង្រីកកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ច ជាពិសេសនៅក្នុងវិស័យសន្តិសុខស្បៀង និងសន្តិសុខថាមពល ។ ឯកឧត្តមរដ្ឋមន្ត្រីទាំងពីរបានគូសបញ្ជាក់អំពីសារសំខាន់នៃការទាញយកផលប្រយោជន៍ពីការបំពេញបន្ថែមសេដ្ឋកិច្ចទៅវិញទៅមក រវាងប្រទេសទាំងពីរ ដើម្បីជំរុញកំណើនប្រកបដោយចីរភាព និងវិបុលភាពរួម ហើយរង់ចាំការចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការស្តីពីសន្តិសុខស្បៀងក្នុងពេលឆាប់ៗខាងមុខ ។

**ការកសាងសមត្ថភាព និងការតភ្ជាប់រវាងប្រជាជននិងប្រជាជន**

ឯកឧត្តមរដ្ឋមន្ត្រីទាំងពីរ បានបញ្ជាក់សាជាថ្មីអំពីតួនាទីដ៏សំខាន់សម្រាប់ការអភិវឌ្ឍធនធានមនុស្ស។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះសិង្ហបុរី ដែលបន្តគាំទ្រកិច្ចការដ៏មានសារសំខាន់នេះ ក៏ដូចជាការយកចិត្តទុកដាក់ដល់ពលករកម្ពុជាដែលកំពុងធ្វើការនៅតាមផ្ទះក្នុងប្រទេសសិង្ហបុរី។ ឯកឧត្តមក៏បានអរគុណសិង្ហបុរីចំពោះការដាក់បញ្ចូលកម្ពុជាទៅក្នុងបញ្ជីនៃប្រភពទីផ្សារការងារមិនមែនប្រពៃណី (NTS) សម្រាប់ការទទួលយកពលករបរទេសទៅធ្វើការ។

ក្រៅពីកិច្ចសហប្រតិបត្តិការលើវិស័យដ៏ទៃទៀត ឯកឧត្តមរដ្ឋមន្ត្រីការបរទេសទាំងពីរក៏បានផ្លាស់ប្តូរទស្សនៈយ៉ាងស៊ីជម្រៅអំពីបញ្ហាតំបន់ និងពិភពលោក ដែលជាក្តីកង្វល់រួម ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានធ្វើបច្ចុប្បន្នភាពអំពីសភាពការណ៍នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និងអំពីស្ថានភាពពលរដ្ឋភៀសសឹកដែលនៅតែមិនអាចវិលត្រឡប់ទៅលំនៅដ្ឋានរបស់ខ្លួនវិញ ។ រដ្ឋមន្ត្រីទាំងពីរក៏បានបញ្ជាក់អំពី ការប្តេជ្ញារួមក្នុងការគាំទ្រផលប្រយោជន៍ស្មូលទៅវិញទៅមក និងធ្វើការយ៉ាងជិតស្និទ្ធ ដើម្បីលើកកម្ពស់សន្តិភាព សន្តិសុខនិងស្ថិរភាពនៅក្នុងតំបន់។

**ឯកឧត្តម ប្រាក់ សុខុន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមបណ្ឌិត វីវៀន បាឡាគ្រីស្សណាន់** ព្រមទាំងក្រុមការងារ ដែលបានរៀបចំទទួលដ៏ល្អឥតខ្ចោះ និងបានផ្តល់បដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅជូនគណៈប្រតិភូកម្ពុជា ក្នុងអំឡុងពេលទស្សនកិច្ចផ្លូវការនេះ ហើយ**ឯកឧត្តម** រង់ចាំឱកាសស្វាគមន៍ **ឯកឧត្តមបណ្ឌិត វីវៀន បាឡាគ្រីស្សណាន់** និងភរិយា អញ្ជើញទៅបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជានាពេលវេលាសមស្រប។

ថ្ងៃពុធ ៨រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៦